ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គំរោងជំនួយ ផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌ នៅកម្ពុជា ដំណាក់កាលទី៣

**របាយការណ៍សង្ខេបការប្រតិបត្តិសកម្មភាព របស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង : មករា - ធ្នូ ២០០៨**

GLOBAL JUSTICE SOLUTIONS (ASIA) PTY LTD

ធ្នូ ២០០៨

Australian Government
AusAID

ផ្តល់មូលនិធិដោយទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ

# របាយការណ៍សង្ខេប

នេះគឺជារបាយការណ៍សង្ខេបពីការរីកចំរើន របស់គំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា ដំណាក់កាល ទី៣ (CCJAP) ដោយយោងលើលទ្ធផលរំពឹងទុកចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០០៨។

អស់រយៈពេល១២ខែកន្លងមកនេះ គម្រោង CCJAP បានបន្តការវិវត្តពីការអនុវត្តគម្រោងដោយខ្លួនឯង ទៅជាការមានទំនាក់ទំនងកាន់តែជិតស្និទ្ធនិងការប្តេជ្ញាចិត្តជួយពង្រឹងភាពជាដៃគូ ការស្វែងរកវិធីសាស្រ្តផ្សេងៗក្នុងការជួយគាំទ្រដល់ការធ្វើកំណែទំរង់កម្មវិធីនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងការធ្វើអោយប្រសើរឡើងនូវប្រសិទ្ធិភាពជំនួយ និងឱកាសធ្វើអោយមាននិរន្តរភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។

តាមរយៈការបង្ហាញពីគោលបំណងប្រសិទ្ធិភាពជំនួយអន្តរជាតិ ដែលនឹងត្រូវលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលជាតិ នៅពេលបន្តិចទៀតនេះ គម្រោង CCJAP នឹង: ពង្រឹងការអភិវឌ្ឍសមត្ថភាពប្រតិបត្តិនិងគាំទ្ររាល់កំណែទំរង់ជាអាទិភាព ការតំរឹមសកម្មភាពរបស់គម្រោងស្របទៅនឹងរចនាសម្ព័ន្ធនិងប្រព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងឱកាសអោយមាននិរន្តរភាព ធ្វើអោយប្រសើរឡើងនូវការសម្របសម្រួលជាមួយម្ចាស់ជំនួយនានា និងភាពជាដៃគូជាមួយសង្គមស៊ីវិល ដែលធ្វើអោយការគាំទ្ររបស់គម្រោងកាន់តែមានប្រសិទ្ធិភាពថែមទៀត ហើយនឹងធ្វើអោយប្រាកដថាកិច្ចខិតខំប្រឹងប្រែងរបស់គម្រោងគឺផ្តោតលើការសំរេចលទ្ធផលជាវិជ្ជមានគឺមិនមែនគ្រាន់តែអនុវត្តការងារដែលយើងមានប៉ុណ្ណោះទេ។

គ្រប់សកម្មភាពរបស់គម្រោងគឺផ្តោតទៅលើការពង្រឹងការប្តេជ្ញាចិត្តទៅលើគ្រប់អន្តរវិស័យដូចជា យុត្តិធម៌អនិតិជនសមភាពយេនឌ័រ ជំងឺអេសដ៍/ មេរោគអេសដ៍ អភិបាលកិច្ចនិងកំរិតស្តង់ដារ និងគាំទ្រដល់ជនងាយរងគ្រោះ។

## ផ្នែកទី១

គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា (CCJAP) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) បន្តសហការជាមួយអង្គភាពគ្រប់គ្រងគម្រោង (PMU) ដើម្បីពង្រឹងមុខងារលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែ

ទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងគាំទ្រការអនុវត្តន៍ទិសដៅកំណែទម្រង់ទូលំទូលាយ។ CCJAP នៅបន្តធ្វើការជាមួយក្រុមការងារបច្ចេកទេសនិងអនុក្រុម ដើម្បីពង្រឹងការធ្វើសមាហរណកម្មវិស័យយុត្តិធម៌ កិច្ចសហប្រតិការអន្តរស្ថាប័ន សុខដុមកម្មនៃដៃគូផ្តល់ជំនួយ និងការដោះស្រាយបញ្ហានៅថ្នាក់ជាតិ។

ផ្នែកនេះបន្តពង្រឹងការអភិវឌ្ឍន៍សមត្ថភាពប្រតិបត្តិ និងការធ្វើសមាហរណកម្មវិស័យតាមរយៈកិច្ចសហប្រតិបត្តិការបន្តបន្ទាប់ ដើម្បីរៀបចំបង្កើតសេចក្តីព្រាងមគ្គុទ្ទេសក៏នៃការធ្វើផែនការតាមវិស័យ និងការរៀបចំប្រព័ន្ធសូចនាករតាមដានកំណែទម្រង់ច្បាប់និងតុលាការ។ សេចក្តីព្រាងមគ្គុទ្ទេសក៏ត្រូវបានដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីសុំយោបល់ និងដើម្បីធានាឱ្យគោលការណ៍មគ្គុទ្ទេសក៏ឆ្លុះបញ្ចាំងតម្រូវការនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

ការងារសហប្រតិបត្តិការជាមួយវិទ្យាស្ថានដាណឺម៉ាកដើម្បីសិទ្ធិមនុស្ស (DIHR) ដើម្បីបន្តរៀបចំប្រព័ន្ធសូចនាករតាមដានសម្រាប់រាជរដ្ឋាភិបាលកម្ពុជាប្រើ។ បន្តជួយដល់អង្គភាពគ្រប់គ្រងគម្រោងដែលធ្វើអង្គភាពគ្រប់គ្រងគម្រោងបង្កើតបាននូវសេចក្តីព្រាងសម្រាប់ជំហាននានាសម្រាប់សកម្មភាពទាំង៩៧ នៃផែនការសកម្មភាពកំណែទម្រង់ច្បាប់និងតុលាការ។ សូចនាករគន្លឹះនៃការតាមដានត្រូវបានរៀបចំឡើង ដើម្បីវាស់បំរែបំរួលនៅក្នុងប្រព័ន្ធតុលាការ និងប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមកំណែទម្រង់។ សូចនាករនេះគ្រោងចាប់ផ្តើមអនុវត្តនៅក្នុងតុលាការគំរូ។

ផ្នែកទី១បន្តគាំទ្រការអភិវឌ្ឍន៍ទស្សនាទានតុលាការគំរូ ដោយសហការជាមួយ EWMI/USAID, DIHR អង្គភាពគ្រប់គ្រងគម្រោង តុលាការ និងក្រសួងយុត្តិធម៌។ ផ្នែកនេះបានរៀបចំបណ្តុះបណ្តាល សិក្ខាសាលា និងជួយតុលាការខេត្តបន្ទាយមានជ័យ ខេត្តកណ្តាល ភ្នំពេញ និងតុលាការខេត្តកំពង់ចាម ក្នុងការរៀបចំផែនការ ការងាររបស់ខ្លួន។

ផ្នែកទី១ក៏បន្តជួយដល់អង្គភាពគ្រប់គ្រងគម្រោងក្នុងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធនានា។ ជំនួយផ្នែកប្រឹក្សាយោបល់ត្រូវបានផ្តល់ទាក់ទងនឹងការរៀបចំយុទ្ធសាស្ត្រទំនាក់ទំនង ព្រមទាំងគាំទ្រដល់ការរៀបចំព្រឹត្តិប័ត្រកំណែទម្រង់ច្បាប់ និងតុលាការផងដែរ។ កិច្ចពិគ្រោះយោបល់រវាងសង្គមស៊ីវិល និងរដ្ឋាភិបាលត្រូវបានគាំទ្រដោយផ្តោតលើការជួបប្រជុំផ្ទាល់ និងតាមរយៈសិក្ខាសាលាតាមខេត្តនានា។

## ផ្នែកទី២

យុទ្ធសាស្ត្រនិរន្តរភាពជាគន្លឹះសំរាប់ផ្នែកនេះ គឺផ្តោតទៅលើការធ្វើសមាហរណកម្មការងារទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាពសហគមន៍ (ទបសស) ចូលទៅក្នុងរចនាសម្ព័ន្ធនៃខេត្តដែលជាដៃគូ។ ការងារនេះបានអនុវត្តរួចមកហើយនៅក្នុងខេត្តកណ្តាល ហើយនៅពេលថ្មីៗនេះក៏បានបន្តអនុវត្តនៅក្នុងខេត្តបាត់ដំបង និងខេត្តព្រៃវែង ជាមួយនិងឆន្ទៈនិងការគាំទ្រយ៉ាងខ្លាំងដែល បានបង្ហាញឱ្យឃើញតាមរយៈការចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀងរវាងអភិបាលខេត្ត ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង និង AusAID ដែលធ្វើឱ្យភាគីទាំង២មានឆន្ទៈប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់របស់រាជរដ្ឋាភិបាលដើម្បីអនុវត្តសកម្មភាព ដែលបានគ្រោងឡើងនិងដើម្បីរៀបចំចាត់ចែងថវិកាផងដែរ។ អនុស្សរណៈនៃកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខាសំរាប់ខេត្តបាត់ដំបងនិងខេត្តព្រៃវែង ហើយនឹងរៀបចំកែសំរួលអនុស្សរណៈថ្មីសំរាប់ខេត្តកណ្តាល។

គណៈកម្មាធិការសំរបសំរួលខេត្តត្រូវបានបង្កើតឡើងជាដៃគូជាមួយនិងខេត្ត ដើម្បីសំរបសំរួលការអនុវត្តយុទ្ធសាស្ត្រកំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ ហើយនិងសកម្មភាពរបស់ CCJAP ហើយនិងដើម្បីគាំទ្រការពង្រឹងនិងប្រើប្រាស់ប្រព័ន្ធនានារបស់ខេត្តដោយ CCJAP ។

នៅក្នុងដំណាក់កាលនេះ សៀវភៅតារាងសកម្មភាពអាទិភាពស្រុកឆ្នាំ២០០៨ ត្រូវបានរៀបចំឡើងដែលឆ្លុះបញ្ចាំងនូវកិច្ចព្រមព្រៀងនៃការគាំទ្រស្រុកចំនួន ៤ និងឃុំចំនួន ៤២ ដើម្បីអនុវត្តសកម្មភាព ទបសស ចំនួន ៦៥ គំរោង នៅក្នុងឆ្នាំ ២០០៨ ដែលក្នុងនេះផ្នែកសន្តិសុខមានចំនួន ៤៦ គំរោង និងផ្នែកយេនឌ័រ មានចំនួន ១៩ គំរោង។ នគរបាលជាតិកម្ពុជាបានសំដែងនូវបំណងក្នុងតួនាទីជាអ្នកដឹកនាំនៅក្នុងសកម្មភាព ទបសស ហើយនឹងពង្រឹងនូវឆន្ទៈរបស់ពួកគេក្នុងការអនុវត្តការងារ ចលនាប្រជាការពារ។

សវនកម្មចំនួន២ត្រូវបានអនុវត្តទៅលើការប្រើប្រាស់ថវិកានៃផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិរបស់ខេត្តកណ្តាល ហើយនិងការចំណាយថវិការបស់មូលនិធិបត់បែន។ មិនមានចំនុចមិនប្រក្រតី ភាពមិនស្របគ្នា ឬភាពមិនត្រឹមត្រូវត្រូវបានរកឃើញទាក់ទងទៅនិងការគ្រប់គ្រងថវិកាទាំងអស់នោះទេ ហើយការគ្រប់គ្រងនោះត្រូវបានទទួលស្គាល់ថាមានគណនេយ្យភាពនិងតម្លាភាព នៅក្នុងការចំណាយដែលស្របជាមួយនិងអនុស្សរណៈនៃកិច្ចព្រមព្រៀង។

គំរោងផែនការនាពេលបច្ចុប្បន្ននេះ គឺធ្វើសេចក្តីព្រាងអនុស្សរណៈនៃកិច្ចព្រមព្រៀងរវាងខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ធំ។

# ផ្នែកទី ៣

អគ្គស្នងការនគរបាលជាតិបានអនុម័តលើផែនការយុទ្ធសាស្ត្ររបស់នគរបាលជាតិកម្ពុជា ដែលផែនការនេះត្រូវបានបង្កើតឡើងដោយមានការសហការពីក្រុមការងារនគរបាលជាតិ។ ផែនការយុទ្ធសាស្ត្រនេះត្រូវបានពិនិត្យឡើងវិញជាបន្ត ហើយក្រុមការងារពីអង្គភាពប្រតិបត្តិការសំខាន់ៗ បានចូលរួមបញ្ចេញទស្សនៈយោបល់លើកំណែផ្សេងៗជាហូរហែរ ដើម្បីបង្កើតឡើងនូវសេចក្តីព្រាងផែនការសកម្មភាព ដោយមានការប្រើប្រាស់មគ្គុទេសក៍ធ្វើផែនការតាមវិស័យជាទិសចង្អុលបង្ហាញសម្រាប់សកម្មភាពរាល់ទាំងឡាយ។

សកម្មភាពផ្នែកកោសល្យវិច័យនៅតែបន្តរឹងមាំ រាប់បញ្ចូលទាំង សមត្ថភាពក្រុមអ្នកជំនាញពីនាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ , សមត្ថភាពស្រាវជ្រាវ និងពិនិត្យកន្លែងកើតហេតុរបស់នគរបាល , ការគ្រប់គ្រងវត្ថុតាង និងពង្រឹងកិច្ចគាំទ្រដល់ជនរងគ្រោះដោយសារអំពើរំលោភផ្លូវភេទ។ សកម្មភាពទាំងនេះបានអនុវត្តនៅតាមបណ្តាខេត្ត-ក្រុងជាដៃគូ ដែលក្នុងនោះមានមន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រជាង៣០០នាក់ទទួលបានការបណ្តុះបណ្តាលព្រមជាមួយផែនការបន្តសកម្មភាពនៅតាមបណ្តាខេត្តបន្ទាប់ៗទៀត។

កម្មវិធីប្រឆាំងការរំលោភបំពានផ្លូវភេទ ដែលមានគោលបំណងការកសាងសមត្ថភាពស៊ើបអង្កេតបទល្មើសរំលោភផ្លូវភេទ និងសម្រាប់ការគាំទ្រដល់ជនរងគ្រោះ ដោយក្នុងនោះមានការចូលរួមពីនគរបាលជាតិកម្ពុជា ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ និងអង្គការក្រៅរដ្ឋាភិបាលដែលមានវិធីសាស្ត្រក្នុង "ប្រព័ន្ធយុត្តិធម៌រួមគ្នា" មួយនៅកម្ពុជា ដោយផ្តោតលើជនរងគ្រោះដោយសារអំពើរំលោភផ្លូវភេទ។ កិច្ចការនេះគឺជាផ្នែកគន្លឹះមួយ និងជាសកម្មភាពសមាហរណកម្មរបស់គម្រោង ដែលមានសក្តានុពលដល់ការពង្រឹង និងពង្រីកនៅតាមបណ្តាខេត្តជាដៃគូ។

បន្តគាំទ្រដល់នគរបាលជាតិកម្ពុជា ក្នុងការបណ្តុះបណ្តាលដល់មន្ត្រីជំនាញកោសល្យវិច័យ និងអ្នកឯកទេសផ្នែកវេជ្ជសាស្ត្រ , ធ្វើអោយប្រសើឡើងនូវសមត្ថភាពកោសល្យវិច័យដើម្បីជាការឆ្លើយតបដល់ក្រុមជនងាយរងគ្រោះនៃបទល្មើសរំលោភផ្លូវភេទ , បង្កើតពិធីសារ និងបទដ្ឋានរបាយការណ៍រួម ជាមួយទីភ្នាក់ងារដែលជាដៃគូសំខាន់ៗ បង្កើតអោយមានភាពជាដៃគូរវាងសង្គមស៊ីវិល និងនគរបាលដើម្បីលើកស្ទួយដល់ការគាំទ្រជនរងគ្រោះ និងដើម្បីបង្ការទប់ស្កាត់បទល្មើស , អភិវឌ្ឍន៍សមត្ថភាពពិនិត្យវាយតម្លៃការធ្វើផែនការប្រតិបត្តិ , ពិនិត្យឡើងវិញ និង

ពង្រឹងសមត្ថភាពប្រមូលវិភាគទិន្នន័យនិន្នាការបទល្មើស , ព្រមទាំងពិនិត្យ និងគាំទ្រដល់ការព្រាងច្បាប់ដែលពាក់ព័ន្ធដែលជាការគាំទ្រដល់គំនិតផ្តួចផ្តើមនេះ និងសម្រាប់នគរបាលជាតិកម្ពុជា។

ក្រុមការងារក្រសួងមហាផ្ទៃ និងនគរបាលជាតិកម្ពុជា ដោយមានការគាំទ្រពីប្រតិភូអូស្ត្រាលី បានជួបប្រជុំគ្នាក្នុងខែកញ្ញា ឆ្នាំ២០០៨ ដើម្បីអនុវត្តដំណើរការជំហានទីមួយនៃការតាក់តែងច្បាប់នេះ។ សេចក្តីព្រាងច្បាប់ក្នុងជំហានទីមួយត្រូវបានបញ្ចប់ ហើយបច្ចុប្បន្នកំពុងចាប់អនុវត្តជំហានបន្តបន្ទាប់លើខ្លឹមសារច្បាប់ដែលបានស្នើឡើង។ ក្រុមការងារពីគ្រប់ភាគី គ្រោងជួបប្រជុំជាបន្តនៅដើមខែកុម្ភៈ ឆ្នាំ២០០៩ ដោយសង្ឃឹមថានឹងអាចបញ្ចប់សេចក្តីព្រាងច្បាប់នេះ នៅមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩។

## ផ្នែកទី៤

សកម្មភាពសំខាន់ៗនៅក្នុងផ្នែកនេះ ផ្តោតជាសំខាន់ទៅលើការបង្កើតសៀវភៅចុះបញ្ជីនីតិជន និងអនីតិជនដែលប្រើប្រាស់នៅក្នុងតុលាការខេត្តកណ្តាលនិងបង្កើតប្រព័ន្ធទិន្នន័យ/ប្រព័ន្ធគ្រប់គ្រងរឿងក្តីសំរាបសាលាឧទ្ធរណ៍។ ចៅក្រមមានភាពស្ទាក់ស្ទើរទាក់ទងទៅនឹងការប្រើប្រាស់សៀវភៅបញ្ជីនេះ ដោយហេតុថានេះជាប្រព័ន្ធថ្មីមួយសំរាប់តុលាការកម្ពុជា ហើយប្រព័ន្ធថ្មីនេះក៏រំពឹងថានឹងដាក់ឱ្យប្រើប្រាស់ផងដែរ។ លោកប្រធានតុលាការខេត្តកណ្តាលបានចាប់ផ្តើមសាកល្បងប្រើប្រាសសៀវភៅនេះ ហើយការសាកល្បងប្រើប្រាស់នេះក៏មានការគាំទ្រផងដែរពី ឯកឧត្តមរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ចៅក្រម និងព្រះរាជអាជ្ញា។ លោកប្រធានតុលាការខេត្តសៀមរាប ជាចៅក្រមម្នាក់ដែលមានបទពិសោធក៏បានស្នើសុំឱ្យមានការផ្តល់ជូនសៀវភៅនេះដល់តុលាការរបស់គាត់ដើម្បីធ្វើការអនុវត្តសាកល្បងផងដែរ។ ការគាំទ្រនេះ គឺជាការលើកកំពស់នូវភាពជោគជ័យសំរាប់ការប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីថ្មីនេះ ហើយនេះបង្ហាញឱ្យឃើញពីឆន្ទៈចូលរួមពាក់ព័ន្ធរបស់ចៅក្រម ជាន់ខ្ពស់និងការគាំទ្ររបស់គាត់សំរាប់ការប្រើប្រាស់ប្រព័ន្ធថ្មីនេះ។

សៀវភៅក្បួននីតិវិធីតុលាការ បន្តប្រើប្រាស់យ៉ាងទូលំទូលាយដោយតុលាការនិងភ្នាក់ងារនានានៅក្នុងវិស័យយុត្តិធម៌និងច្បាប់។ ការពិនិត្យកែសំរួលឡើងវិញសៀវភៅនេះ កំពុងដំណើការអនុវត្តដោយគណៈកម្មការដែលមានសមាសភាពមកពីក្រសួងយុត្តិធម៌ និងចៅក្រម ព្រមទាំងដោយមានការគាំទ្រពីគំរោង CCJAP ផងដែរ។

ការងារសំរាប់ផ្នែកនេះ នឹងបន្តជួយគាំទ្រដល់ផ្នែកទី ១ និងអង្គការ DANIDA ដើម្បីបង្កើតនិងអនុវត្តទស្សនៈតុលាការគំរូនៅក្នុងខេត្តដែលជាដៃគូរនានា។ លើសពីនេះទៅទៀតសកម្មភាពនានា ដែលនឹងគាំទ្រដល់ការអនុវត្តតុលាការគំរូនៅក្នុងខេត្តជាដៃគូរសំរាប់ផែនការឆ្នាំ ២០០៨/២០០៩។ នេះជាសកម្មភាពសំខាន់រួមធ្វើយ៉ាងណាដើម្បីបង្កើនការធ្វើសមាហរណកម្ម និងឱកាសសំរាប់ធ្វើឱ្យមាននិរន្តរភាព។

ដំណើការរៀបចំទិន្នន័យសំរាប់សាលាឧទ្ធរណ៍ កំពុងមានភាពជឿនលឿនទៅមុខយ៉ាងល្អប្រសើរដោយបានបំពាក់នូវប្រព័ន្ធ Server នៅក្នុងតុលាការ ហើយការតេស្តសាកល្បងប្រព័ន្ធនេះកំពុងដំណើការមុនពេលបំពាក់ Server។ គំរោង CCJAP ក៏បានជួយបំពាក់ប្រព័ន្ធថតសំលេងនៅក្នុងសាលសវនាការផងដែរដែលប្រព័ន្ធនេះនឹងបំពាក់រួចរាល់នៅក្នុងសប្តាហ៍នៃថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ នេះ។ គំរោងក៏បានជួយដល់សាលាឧទ្ធរណ៍ក្នុងការរៀបចំសំណុំរឿងដោយបានជួលបុគ្គលិកពីខាងក្រៅចំនួន ៣ នាក់ ដើម្បីរៀបចំសំណុំរឿងចាស់ នឹងសំណុំរឿងបច្ចុប្បន្នរក្សាទុកនៅក្នុងបន្ទប់ដែលឧបត្ថមជួសជុសដោយគំរោង CCJAP ។ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍បានទទួលការបណ្តុះបណ្តាលកំព្យូទ័រអំពីការប្រើប្រាស់កម្មវិធី Word និង Excel ដែលគំរោងបានផ្តល់ជូននូវកំព្យូទ័រនេះរួចហើយ។ កំព្យូទ័ររបស់ចៅក្រមនិងព្រះរាជអាជ្ញា នឹងត្រូវភ្ជាប់បណ្តាញផ្ទៃក្នុងដែលបណ្តាញនេះ នឹងជួយដល់ការផ្លាស់ប្តូរព័តិមានឱ្យគ្នាទៅវិញទៅមកសំដៅការប្រើប្រាស់នៅក្នុងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ទាំងមូលព្រមទាំងធ្វើយ៉ាងណា ដើម្បីធ្វើឱ្យប្រសើរឡើងនូវរយៈពេលនៃការដំណើការរឿងក្តីទាក់ទងទៅនឹងការដំណើការបញ្ចប់រឿងក្តីឱ្យបានឆាប់រហ័ស ហើយនៅពេលដែលភ្ជាប់ដំណើការនេះជាមួយនឹងប្រព័ន្ធថតសំលេងតុលាការដោយប្រព័ន្ធអ៊ីឡិចត្រូនិចនោះ វានឹងជួយធ្វើឱ្យប្រសើរឡើងនូវគុណភាពនិងពេលវេលានៃការសំរេចរបស់តុលាការ។

ការជួយគាំទ្រ ក៏ត្រូវផ្តោតផងដែរទៅលើវិស័យដែលផ្តោតយកចិត្តទុកដាក់ផ្សេងៗ និងបញ្ហាដែលពាក់ព័ន្ធគ្នាដែលត្រូវអនុវត្តដោយទីប្រឹក្សាយុត្តិធម៌អនីតិជនរយៈពេលខ្លី ដើម្បីជួយដល់ក្រសួងយុត្តិធម៌ទាក់ទងនឹងការងារយុត្តិធម៌អនីតិជន។ ថ្មីៗនេះក្រុមសីលធម៌ និងអភិបាលកិច្ចល្អក៏បានទទួលការជួយគាំទ្រតាមរយៈអគ្គាធិការដ្ឋានកិច្ចការតុលាការរបស់ក្រសួងយុត្តិធម៌ផងដែរ។ គំរោងក៏បានជួយគាំទ្រដល់ការងារយែនឌ័រ នៅក្នុងក្រសួងយុត្តិធម៌តាមរយៈការបង្កើតនូវសេចក្តីព្រាងផែនការសកម្មភាពសំរាប់ក្រសួងយុត្តិធម៌ និងជួយដល់ការបោះពុម្ពផ្សព្វផ្សាយផែនការនេះនិងធ្វើការបណ្តុះបណ្តាលនៅពេលដែលផែនការនេះអនុម័តរួច។ គំរោងក៏បានជួយគាំទ្រខាង HIV/AIDS តាមរយៈទីប្រឹក្សារយៈពេលខ្លីដែលរបាយការណ៍អំពីការងារនេះនឹងត្រូវផ្សព្វផ្សាយនៅដើមឆ្នាំ២០០៩ ខាងមុខនេះ។

ការបង្កើនសមត្ថភាពដល់ថ្នាក់ដឹកនាំ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សជាយុទ្ធសាស្ត្រកំពុងដំណើរការពិនិត្យឡើង វិញ ដែលទំហំការងារនេះនឹងអនុវត្តដោយទីប្រឹក្សារយៈពេលខ្លីម្នាក់រួមសហការជាមួយតំណាងក្រសួងយុត្តិធម៌ ដោយអនុវត្តទៅតាមអនុសាសន៍ និងសកម្មភាពនានា ដែលមានផែនការអនុវត្តសំរាប់ឆ្នាំ ២០០៨/ ២០០៩។

ក្នុងរយៈពេលអនុវត្តសកម្មភាព ៣ ខែបន្ទាប់ គំរោង នឹងផ្តោតទៅលើការបោះពុម្ព និងផ្សព្វផ្សាយផែនការសកម្មភាព យៃនឌ័ររបស់ក្រសួងយុត្តិធម៌។ លើសពីនេះទៀត ការបង្កើតទិន្នន័យសំរាប់សាលាឧទ្ធរណ៍ និងការបង្កើតជាបន្តបន្ទាប់នូវការអនុវត្តទិន្នន័យរបស់តុលាការ។ សាលាឧទ្ធរណ៍នឹងទទួលបានសំភារៈឧបករណ៍ថតសំលេងរបស់តុលាការ ដែលការងារនេះនឹងធ្វើការបណ្តុះបណ្តាលដល់ក្រឡាបញ្ជីតុលាការដើម្បីអនុវត្តបច្ចេកវិជ្ជានេះ។ វគ្គបណ្តុះបណ្តាលអំពីការសរសេរសាលក្រម សំរាប់ចៅក្រមដែល ធ្វើការនៅសាលាឧទ្ធរណ៍ តុលាការកំពូល និងចៅក្រមមកពីសាលាក្តីខ្មែរក្រហមនឹងត្រូវផ្តល់ដោយគំរោង CCJAP ដែលអនុវត្តដោយចៅក្រមជនជាតិបារាំងជាអ្នកធ្វើការបណ្តុះបណ្តាលផ្ទាល់។

ការអនុវត្តសាកល្បងសៀវភៅចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌ នឹងបន្តអនុវត្តនៅតុលាការខេត្តកណ្តាល និងខេត្តសៀមរាប ហើយទិន្នន័យដែលត្រូវដកចេញពីនេះ នឹងអាចទទួលបាននៅដំណាច់ខែ មីនា ឆ្នាំ ២០០៩ ខាងមុខនេះ។ សកម្មភាពការងារក្នុងផ្នែកនេះ នឹងបន្តបង្កើតផែនការសំរាប់ការជួសជុលតុលាការខេត្តព្រៃវែង និងតុលាការខេត្តបាត់ដំបង។ ជំនួយដែលមានការសហការួមគ្នាជាមួយអង្គការ EWMI ក៏នឹងជំរុញឱ្យមាន ការអនុវត្តដើម្បីពង្រឹងដល់ការងារដល់អគ្គាធិការដ្ឋានក្រសួងយុត្តិធម៌។ គំរោងក៏ជួយគាំទ្រដល់ក្រុមការងារយុត្តិធម៌អនីតិជនរបស់ក្រសួងយុត្តិធម៌តាមរយៈការជួយផ្តល់យោបល់ទៅលើសេចក្តីព្រាងស្តីពីច្បាប់យុត្តិធម៌អនីតិជន។

## ផ្នែកទី៥

នៅក្នុងអំឡុងពេលនេះ ទីប្រឹក្សារយៈពេលខ្លីសំរាប់ធ្វើសេចក្តីព្រាងច្បាប់ពន្ធនាគារបានចាប់ផ្តើមពិនិត្យឡើងវិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងគោលនយោបាយនានា ដែលមានបច្ចុប្បន្ន ហើយបន្ទាប់មកក៏បានបង្កើតជាសេចក្តីណែនាំ និងអនុសាសន៍នានាដែលជាមូលបទសំខាន់ៗនៃគ្រោងឆ្អឹងរបស់សេចក្តីព្រាងច្បាប់សំរាប់ជួយគាំទ្រដល់ការអនុវត្តន៏ច្បាប់ថ្មីនេះ។ បច្ចុប្បន្នសមាភាគីសំខាន់ៗនៃអគ្គនាយកដ្ឋានពន្ធនាគារក៏កំពុងតែរៀបចំផែនការបន្ត ដើម្បីធ្វើឱ្យសេចក្តីព្រាងច្បាប់នេះមានភាពរីកចំរើនទៅមុខថែមទៀត។

អគ្គនាយកដ្ឋានពន្ធនាគារបានទទួលការជួយគាំទ្រផងដែរ ក្នុងការពិនិត្យកែសំរួលឡើងវិញនូវផែនការ យុទ្ធសាស្ត្រ ហើយផែនការនេះក៏បានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ក្រសួងមហាផ្ទៃ ទន្ទឹមនឹងនោះក៏បាន ជួយអភិវឌ្ឍន៍នូវតួនាទីនិងភារកិច្ចថ្នាក់នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធនាគារ ក្នុងនោះរួមមានការិយាល័យ តាមដានមូលដ្ឋាន។ ការជួយបង្កើតតួនាទីនិងភារកិច្ចរបស់ការិយាល័យតាមដានមូលដ្ឋាន នឹងជួយពង្រឹងដល់ អភិបាលកិច្ចនិងការទទួលខុសត្រូវនៅក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារ ហើយក៏ជាសកម្មភាពផ្តោតជាចំបងសំរាប់ ការងារអភិបាលកិច្ច និងលិខិតបទដ្ឋាននៅក្នុងផែនការឆ្នាំ២០០៨ - ២០០៩ផងដែរ។

នៅក្នុងអំឡុងពេលនេះ ក៏បានធ្វើសិក្ខាសាលាថ្នាក់ជាតិ ដើម្បីកំណត់នូវ **ទិសដៅអនាគត** ហើយក៏មានការ ចូលរួមចំណែកពីដៃគូរចូលរួមសំខាន់ៗ និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលពាក់ព័ន្ធ។ សិក្ខាសាលាបែបនេះ គឺជាគំនិតផ្តួចផ្តើមថ្មីដ៏សំខាន់របស់អគ្គនាយកដ្ឋានពន្ធនាគារ។

ការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីថ្នាក់គ្រប់គ្រង និងថ្នាក់ដឹកនាំត្រូវបានជួយគាំទ្រតាមរយៈសកម្មភាពធ្វើផែនការ បណ្តុះបណ្តាលនិងយុទ្ធនាការលើកកំពស់ការយល់ដឹងផ្សេងៗ។ គំរោង CCJAP បានជួយអគ្គនាយកដ្ឋានពន្ធនាគារ ក្នុងការបង្កើតកំរងសំណួរ ស្តីពីការវាយតំលៃសមត្ថភាពផ្ទាល់ខ្លួនសំរាប់ថ្នាក់ដឹកនាំនិងថ្នាក់គ្រប់គ្រង។ ម្យ៉ាងទៀត គំរោង CCJAP បានជួយគាំទ្រដល់ក្រុមការងារយេនឌ័ររបស់អគ្គនាយកដ្ឋានពន្ធនាគារក្នុងការបង្កើតផែនការ សកម្មភាពយេនឌ័រ ហើយផែនការនេះនឹងត្រូវបានអនុវត្តដោយមានការជួយគាំទ្រតាមរយៈផែនការយុទ្ធសាស្ត្រ យេនឌ័ររបស់គំរោង CCJAP និងទីប្រឹក្សាយេនឌ័ររយៈពេលខ្លី។ គំរោង CCJAP និងអគ្គនាយកដ្ឋានពន្ធនាគារ បានអភិវឌ្ឍន៍រួមគ្នានូវសេចក្តីព្រាងកម្មវិធីបណ្តុះបណ្តាលសំរាប់មន្ត្រីពន្ធនាគារ និងមន្ត្រីថ្នាក់គ្រប់គ្រងហើយនឹង ត្រូវអនុវត្តនៅក្នុងផែនការឆ្នាំ២០០៨-២០០៩។ អគ្គនាយកដ្ឋានពន្ធនាគារនិងគំរោង CCJAP បានបង្កើតកម្មវិធី អភិវឌ្ឍន៍ធនធានមនុស្ស ហើយកម្មវិធីនេះបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

គំរោង CCJAP នៅតែបន្តជួយគាំទ្រអគ្គនាយកដ្ឋានពន្ធនាគារនិងក្រសួងសុខាភិបាលក្នុងការបណ្តុះបណ្តាលមន្ត្រី ពេទ្យនិងទិដ្ឋភាពនានានៃសុខភាពក្នុងពន្ធនាគាររួមមានមេរោគអេដស៍-ជម្ងឺអេដស៍តាមរយៈការសិក្សាស្រាវជ្រាវ ជាមួយអង្គការ UNODC ដើម្បីដោះស្រាយបញ្ហាមេរោគអេដស៍-ជម្ងឺអេដស៍នៅក្នុងពន្ធនាគារ។ ការសិក្សាស្រាវជ្រាវ ធ្វើឡើងជាមួយអង្គការ CRS ដើម្បីវាយតំលៃនូវសេចក្តីត្រូវការសំរាប់ផ្តល់សេវាអំពីជម្ងឺអេដស៍នៅក្នុងពន្ធនាគារ។ ម្យ៉ាងទៀតបានជួយសម្របសម្រួលសិក្ខាសាលារវាងអគ្គនាយកដ្ឋានពន្ធនាជាមួយអង្គការដែលជាដៃគូរសំខាន់ៗអំ

ពីការកាត់បន្ថយមេរោគអេដស៍-ជម្ងឺអេដស៍ និងរបេងនៅក្នុងពន្ធនាគារ។ គំរោងបានរួមគ្នាជាមួយអគ្គនាយកដ្ឋានពន្ធនាគារ រៀបចំសេចក្តីណែនាំអំពីសុខភាពក្នុងពន្ធនាគារ។ គំរោង CCJAP នៅតែបន្តធ្វើការជាមួយក្រសួងសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីធ្វើឱ្យសេវាសុខភាពក្នុងពន្ធនាគារមានភាពប្រសើរឡើងនៅតាមបណ្តាពន្ធនាគារដែលជាដៃគូរជាមួយគំរោង។

ភាពចង្អៀតណែននៅតាមពន្ធនាគារគឺជាហានិភ័យចំបងបំផុតចំពោះសេវាសុខភាពក្នុងពន្ធនាគារ ទន្ទឹមនឹងពេលដែលចំនួនអ្នកទោសចេះតែកើនជានិច្ច។ បញ្ហានេះអាចត្រូវបានដោះស្រាយតាមរយៈយុទ្ធសាស្ត្រសមស្របក្នុងប្រព័ន្ធយុត្តិធម៌ជារួមដោយបង្កើតជាយន្តការផ្តន្ទាទោសតាមជំរើសផ្សេងៗ ដូចជាកម្មវិធីផ្តន្ទាទោសតាមជំរើស ផ្សេងៗរបស់តុលាការ សេវាកម្មបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទា ព្រមទាំងកម្មវិធីដោះលែងដោយមានលក្ខខ័ណ្ឌជាដើម។ យុទ្ធសាស្ត្រដោះស្រាយបែបនេះទាមទារឱ្យមានការសហប្រតិបត្តិការយ៉ាងពេញលេញពីសំណាក់អង្គភាពគ្រប់គ្រងគំរោង(PMU) តុលាការ នគរបាល និងពន្ធនាគារទើបអាចកាត់បន្ថយបាននូវភាពមិនរាងចាល និងភាពចង្អៀតណែននៅក្នុងពន្ធនាគារ។

សេចក្តីព្រាងស្តីពីក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារដែលផ្តោតលើការស្តារនីតិសម្បទានិងសមាហរណកម្មអ្នកទោសតាមរយៈឧស្សាហកម្មនិងកសិកម្មពន្ធនាគារត្រូវបានបញ្ចប់និងបានផ្សព្វផ្សាយ តាមរយៈសិក្ខាសាលាជាតិដោយមានការចូលរួមផ្តល់ជាអនុសាសន៍ពីអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ។ ក្របខណ្ឌគោលនយោបាយកំណែទម្រង់នេះបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃហើយកំពុងត្រូវបានអនុវត្ត។ ម្យ៉ាងវិញទៀតក៏បានបង្កើតនីតិវិធីគ្រប់គ្រងឧស្សាហកម្មនិងកសិកម្មពន្ធនាគារ ព្រមទាំងបានបណ្តុះបណ្តាលដល់ប្រធានពន្ធនាគារអំពីការអនុវត្តន៍នីតិវិធីនេះ។ កម្មវិធីឧស្សាហកម្មនិងកសិកម្មពន្ធនាគារកំពុងត្រូវបានអនុវត្តសាកល្បងនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារធំៗមួយចំនួន រួមមានដូចជា ពន្ធនាគារខេត្តកណ្តាល និងបាត់ដំបង។

តំណាងអគ្គនាយកដ្ឋានពន្ធនាគារបានចូលរួមប្រជុំថ្នាក់ខេត្តរវាងតុលាការ នគរបាល និងពន្ធនាគារ ហើយបានលើកយកបញ្ហាអំពីគោលនយោបាយបន្ធូរបន្ថយទោស និងលើកលែងទោសមកពិភាក្សាជាមួយតំណាងក្រសួងយុត្តិធម៌ ព្រះរាជអាជ្ញា តុលាការ និងប្រធានពន្ធនាគារផងដែរ។

## ផ្នែកទី ៦

ពេលនេះ សមភាគីនិងដៃគូពាក់ព័ន្ធសំខាន់ផ្សេងទៀតត្រូវបានផ្តល់ឱកាសអោយមានការទាក់ទងក្នុងការអភិវឌ្ឍន៍ផែនការប្រចាំឆ្នាំនិងផែនការប្រចាំឆ្នាំបន្តសំរាប់ឆ្នាំ២០០៨/២០០៩។ ផែនការគ្រប់គ្រងហានិភ័យឡើងវិញ ការកំណត់និងធ្វើអោយប្រសើរឡើងនៃការត្រួតពិនិត្យនិងវាយតំលៃសកម្មភាពការងារ និងការធ្វើសេចក្តីព្រាងមគ្គុទ្ទេសក៍នៃការធ្វើផែនការក្នុងវិស័យយុត្តិធម៌។

នីតិវិធីប្រតិបត្តិការគម្រោងត្រូវបានកែសំរួលឡើងវិញនិងអនុម័តដោយ AusAID រីឯគោលការណ៍មូលនិធិបត់បែននិងដំណើរការអនុម័តនឹងត្រូវកែសំរួលឡើងវិញផងដែរដោយមានការអនុម័តពីក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោង និង AusAID ។ មានក្រុមហ៊ុនសវនកម្មចំនួនពីរដែលបានធ្វើសវនកម្មលើនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងគម្រោង និងមូលនិធិបត់បែនក្នុងកំឡុងពេលនេះ។ ការផ្តល់អនុសាសន៍លើនីតិវិធីខ្លះៗត្រូវបានអនុវត្តដើម្បីបំពេញតាមតំរូវការក្នុងការធ្វើអោយមានគណនេយ្យភាពនិងតម្លាភាពនៅពេលប្រតិបត្តិការសកម្មភាព។ ការកែសំរួលមូលនិធិបត់បែនត្រូវបានពន្យល់ជូនអ្នកពាក់ព័ន្ធសំខាន់ៗ អំពីនីតិវិធីមូលនិធិបត់បែនថ្មីនិងការកែសំរួលគោលការណ៍មួយចំនួន។

យុទ្ធសាស្ត្របញ្ច្រាបយេនឌ័រត្រូវបានពង្រាងនឹងត្រៀមដាក់អោយអនុវត្តនៅក្នុងឆ្នាំ២០០៨។ ផែនការសកម្មភាពត្រូវបានអភិវឌ្ឍនិងបានអនុវត្តជាមួយដៃគូភ្នាក់ងារ ដោយមានការគាំទ្រដល់ក្រសួងកិច្ចការនារីក្នុងការជួយជំរុញអោយការអនុវត្តបានបញ្ចប់តាមពេលកំណត់។

សេចក្តីព្រាងយុទ្ធសាស្ត្រយុត្តិធម៌អនីតិជន និងជំងឺអេសដ៍/មេរោគអេសដ៍ គឺកំពុងស្ថិតនៅក្នុងការអភិវឌ្ឍនៅឡើយ ដូច្នេះក្រុមប្រឹក្សាភិបាលជាតិនឹងផ្តល់ជូននូវទិដ្ឋភាពរួមអំពីយុទ្ធសាស្ត្រទាំងពីរនេះ។

ការអនុវត្តសកម្មភាពគម្រោងទាំងមូលប្រកបដោយភាពជោគជ័យ និងមានចំនុចមួយចំនួនចាំបាច់ត្រូវតែពង្រឹងដើម្បីអោយមាននិរន្តរភាព។ ទំនាក់ទំនងការងារជាមួយសមភាគី និងដៃគូពាក់ព័ន្ធសំខាន់ៗភាគច្រើនគឺមានភាពល្អប្រសើរ ហើយអាចអភិវឌ្ឍន៍ ពង្រឹងបន្ថែមទៀត និងដើម្បីជំរុញ និងធ្វើឱ្យប្រាកដថាការអនុវត្តសកម្មភាពគឺកាន់តែមានប្រសិទ្ធភាព ហើយនិងមាននិរន្តរភាពយូរអង្វែង។

ក្នុងកំឡុងពេលនេះ គម្រោងបានសំរេចរាល់គំរោងផែនការការងារសាងសង់ ដើម្បីរៀបចំចាប់ផ្តើមការងារសាងសង់ជាមួយដៃគូ ទោះជាយ៉ាងណាក៏ដោយ ការងារសាងសង់គឺមានភាពយឺតយ៉ាវ ។ មន្ត្រីគម្រោងនិងសមភាគីត្រូវបានពន្យល់ណែនាំនិងបណ្តុះបណ្តាលអំពីដំណើរការដេញថ្លៃ វិធីសាស្ត្រធ្វើអធិការកិច្ចលើការងារសាងសង់ វិធីសាស្ត្រធ្វើលទ្ធកម្ម ហើយនឹងការត្រួតពិនិត្យគុណភាព។ នីតិវិធីលទ្ធកម្មត្រូវបានកសាងឡើង រីឯឧបករណ៍សម្ភារៈត្រូវបានបំពាក់ជូន និងផ្តល់ការបណ្តុះបណ្តាលក្នុងគោលបំណងដើម្បីរក្សាសុវត្ថិភាពតាមក៏រិតស្តង់ដារ ដល់មន្ត្រីតំណាងអគ្គនាយកដ្ឋានពន្ធនាគារ ដែលនឹងត្រូវប្រើប្រាស់កំលាំងពលកម្មអ្នកទោសក្នុងក្របខណ្ឌឧស្សាហកម្មពន្ធនាគារដើម្បីគាំទ្រដល់ដំណើរការសាងសង់។ បញ្ហាមួយចំនួនទាក់ទងនឹមុខងាររបស់ថ្នាក់ជាតិ និងគណៈកម្មាធិការប្រតិបត្តិថ្នាក់ខេត្តក្នុងនីតិវិធីធ្វើលទ្ធកម្មនៃការងារសាងសង់នឹងត្រូវធ្វើការដោះស្រាយ ដើម្បីអោយការងារសាងសង់មានដំណើរការទៅមុខ។ ការងារជួសជុលមួយចំនួនបានចាប់ផ្តើមនៅមណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ និងនៅពន្ធនាគារភ្នំពេញ។

បុគ្គលិកគម្រោងចំនួន ៣ នាក់បានលាឈប់ពីការការងារ ដែលមាន:

- លោក **ឡារី ប្រោជ** ជាប្រធានក្រុមអូស្ត្រាលី បានលាឈប់ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨
- លោកស្រី **នួន សុខជា** ជាមន្ត្រីគម្រោងផ្នែកយេនឌ័រ បានលាឈប់ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨
- លោក **អៀន ម៉ប់ហ៊ី** ជាទីប្រឹក្សាតុលាការ ក៏នឹងត្រូវលាឈប់ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩

ដំណើរការជ្រើសរើសមនុស្សជំនួសមុខងារប្រធានក្រុមអូស្ត្រាលីស្ទើរតែបញ្ចប់ទាំងស្រុងហើយ។ គណៈកម្មការជ្រើសរើសមាន ឯកឧត្តម **ស៊ុយ ម៉ុងលាង** លោកស្រី **Arthi Patel** តំណាង **AusAID** លោក **Glenn Crannage** តំណាងក្រុមហ៊ុន **GJS**។ ការប្រកាសលទ្ធផលនឹងជូនដំណឹងនៅពេលឆាប់ៗនេះ។

ការជ្រើសរើសទីប្រឹក្សាតុលាការ និងមន្ត្រីគម្រោងផ្នែកយេនឌ័រនិងយុត្តិធម៌អនីតិជន នឹងត្រូវជ្រើសរើសនៅខែក្រោយ។